ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣០/១៣-ឃែនធើរេន អ៊ីភែរីល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៣

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **អន ណន**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល (ខេមបូឌា)**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង ផ្លូវវែងស្រែង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៨៥២ ២០០ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជកចូលរួម ៖

១- លោក លាវ គីមប៊ូ ប្រធានរដ្ឋបាល

២- លោក ឃឿង សៀន ជំនួយការរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ក/ឈ្មោះ ៖ **-សហព័ន្ធសហជីពការពារសិទ្ធិកម្មករ**

**-សហជីពការពារសិទ្ធិកម្មករនៃក្រុមហ៊ុន ឃែនធើរេន អ៊ីភែរីល**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង ផ្លូវវែងស្រែង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៨ ៨៨ ១១១ ៦៦ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួម ៖ អវត្តមាន

ខ/ឈ្មោះ ៖ **-សហព័ន្ធសហជីពដើម្បីសិទ្ធិការងារ**

**-សហជីពដើម្បីសិទ្ធិការងារនៃក្រុមហ៊ុន យៃនធើរេន អីតែរីល**

អាសយដ្ឋាន ៖ ភូមិត្រពាំងថ្លឹង ផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០១២ ៥៤ ៩៩ ៤៥ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិតចូលរួម ៖ អវត្តមាន

## បញ្ហាក្តុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់អតីតភាពការងាររបស់កម្មករចំនួន ១២០ ដុល្លារ ក្នុងមួយឆ្នាំ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ចំពោះប្រាក់អតីតភាពការងាររបស់កម្មករ ក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់អាហារថ្ងៃត្រង់ចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់ឱ្យឡើយ ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ១២ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ចំពោះប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅ ក្រុមហ៊ុនផ្តល់ឱ្យចំនួន ៧ ដុល្លារ ក្នុងមួយខែ តាមសេចក្តីជូនដំណឹងរបស់ក្រសួង ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែក ទីពីរ(ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ៧៤០ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទជួបប្រជុំមុនសវនាការ ៖** ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៣ (វេលាម៉ោង ១៥ និង ០០ នាទី រសៀល) ។
**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០១៣ (វេលាម៉ោង ១៤ និង ០០ នាទី រសៀល) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានវិវាទការងារ បានទទួលលិខិតអញ្ជើញរបស់ក្រុមហ៊ុន ឃែនធែរេន អីភែរីល (ខេមបូឌា) ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការស្នើសុំអ្នកផ្សះផ្សាជួយដោះស្រាយករណីកម្មករនិយោជិត ទាមទារឱ្យក្រុមហ៊ុនកែលំអនូវលក្ខខណ្ឌការងារមួយចំនួនឱ្យបានល្អប្រសើរ ។ បន្ទាប់ពីបានទទួលលិខិតអញ្ជើញនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ០១ ចំណុច លើការទាមទារចំនួន ០៤ ចំណុច ។ ចំណុចមិនសះជាដែលនៅសល់ ចំនួន ០៣ ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ឃែនធែរេន អីភែរីល (ខេមបូឌា) លេខ ៧៤០ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣ ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះមក ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលពត៌មានថា កម្មករនិយោជិតបានធ្វើកូដកម្ម ហើយកម្មករនិយោជិតនៅតែធ្វើកូដកម្មនៅតែបន្ត បន្ទាប់ពីក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿងនេះ ។ នាយកក្រុមហ៊ុន ឃែនធែរេន អីភែរីល (ខេមបូឌា) បានធ្វើលិខិតសំណើមួយ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ មកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីសុំឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន ឃែនធែរេន អីភែរីល (ខេមបូឌា) ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជា លេខ ០២៨/១៣ កបអ. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ ដើម្បីបញ្ជាឱ្យកម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿង នេះ ផ្អាកការធ្វើកូដកម្ម រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាល ត្រូវបានបញ្ចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ តទៅ ទៅតាមវេនរបស់ខ្លួន ប៉ុន្តែកម្មករនិយោជិតមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះទេ ។ ដូច្នេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកចូលរួមប្រជុំនៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ វេលាម៉ោង ៣ រសៀល ដើម្បីសាកសួរព័ត៌មានអំពីការធ្វើកូដកម្មនេះ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលការជូនដំណឹងពីភាគីនិយោជក និងភាគីកម្មករនិយោជិតថា កម្មករនិយោជិតបានចូលធ្វើការជាធម្មតាវិញហើយ ។ ហេតុនេះ មិនមានការជួបប្រជុំរវាងក្រុមអាជ្ញាកណ្តាល និងភាគីទាំងពីរ ដើម្បីសាកសួរព័ត៌មានកូដកម្ម នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣ ទេ ។

តាមរយៈកំណត់ហេតុប្រជុំផ្សះផ្សា ស្តីពីការពិនិត្យ សម្របសម្រួល និងដោះស្រាយករណីធ្វើកូដកម្មរបស់កម្មករនិយោជិត រោងចក្រ ឃែនធែរេន អីភែរីល (ខេមបូឌា) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ *(ដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយភាគីក្រុមហ៊ុន នៅថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៣)* ក្រុមប្រឹក្សាអាជ្ញាកណ្តាល

រកឃើញថា ភាគីនិយោជក និងភាគីកម្មករនិយោជិត បានព្រមព្រៀងគ្នា ត្រង់ចំណុចវិវាទទី២ និងទី៣ នៃសំណុំរឿងនេះ។

បន្ទាប់ពីបានទទួលព័ត៌មានពីការត្រលប់ចូលធ្វើការរបស់កម្មករនិយោជិតនេះមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចវិវាទមិនសះជាដែលនៅសល់ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល ប៉ុន្តែភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការ ដោយមិនបានបញ្ជាក់ពីមូលហេតុត្រឹមត្រូវណាមួយឡើយ ដោយគ្រាន់តែបញ្ជាក់ថា មិនអាចចូលរួមសវនាការបានទេ ដោយសារជាប់រវល់។ ចំណែកភាគីនិយោជកវិញ បានមកចូលរួមសវនាការ តាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដោយបានបញ្ជាក់ថា នៅក្នុងការប្រជុំផ្សះផ្សា រវាងភាគីនិយោជក និងភាគីកម្មករនិយោជិត នាថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ភាគីកម្មករនិយោជិតបានព្រមព្រៀងដកការទាមទារនៅក្នុងចំណុចវិវាទទី១ រួចហើយ ប៉ុន្តែភាគីទាំងពីរភ្លេចចំលងចូលនៅក្នុងកំណត់ហេតុនៃការប្រជុំ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣ របស់ក្រុមហ៊ុន ឃែនធើរែន អ៊ីភែរីល (ខេមបូឌា) គោរពជូនក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំចេញសេចក្តីបញ្ជា ដើម្បីផ្អាកការធ្វើកូដកម្មរបស់កម្មករនិយោជិត នៅក្រុមហ៊ុន ឃែនធើរែន អ៊ីភែរីល (ខេមបូឌា)។

២- កំណត់ហេតុប្រជុំផ្សះផ្សា ស្តីពីការពិនិត្យ សម្របសម្រួល និងដោះស្រាយករណីធ្វើកូដកម្មរបស់កម្មករនិយោជិត រោងចក្រ ឃែនធើរែន អ៊ីភែរីល (ខេមបូឌា) ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ឃែនធើរែន អ៊ីភែរីល (ខេមបូឌា) លេខ ៧៤០ កប/អក/វក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ឃែនធើរែន អ៊ីភែរីល ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០២៨/១៣ កបអ. ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣។

THE ARBITRATION COUNCIL

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ៦៤២ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

៣- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ៦៤៣ កប/អក/វក/លកអ. ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ។

៤- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ៦៥៦ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ។

៥- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ៦៥៧ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា ភាគីកម្មករនិយោជិតបានអវត្តមាននៅថ្ងៃសវនាការ ដោយគ្មានបញ្ជាក់មូលហេតុត្រឹមត្រូវ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

នៅក្នុងសំណុំរឿងនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើចំណុចវិវាទមិនសះជាដែលនៅសល់ នៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល ប៉ុន្តែភាគីកម្មករនិយោជិតមិនបានមកចូលរួមសវនាការទេ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម ៖

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រង់ប្រការ ២១ ចែងថា ៖ *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួន ក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា៖ *"ប្រសិនបើភាគីណាមួយ មិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាលត្រូវតែបំពេញតាមលក្ខខណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងនៃដំណើរការអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសម្រេចរបស់ខ្លួន"* ។

ផ្អែកលើ ២១ និងវិធាន ៤.៧ ខាងលើនេះ នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន។ លក្ខខណ្ឌទី១ គឺភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ, លក្ខខណ្ឌទី២ គឺ

ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ គឺភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលសំណុំរឿងលេខ ៣០/០៥-មូរៀ, លេខ ១៦/០៧-ឡូទូសតី, លេខ ២៧/០៧-អ៊ឹម និង វេ ៣, លេខ ៩៥/០៨-យ៉ុង វ៉ា ទី១, លេខ ១៣២/០៨-ជី អេច ជី, លេខ ១៣៨/០៨-ម៉ាលីន ហ្គាមិន, លេខ ១៥១/០៨-វិល សិន, លេខ ០៥/០៩-នីមប៊ីស ថិចថាយ ,លេខ ០១/១០-ខិនទីតិច និង លេខ ៣០/១០-ក្លូប័ល អាប៉ារែល)* ។

យោងតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ និងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះយល់ស្របថា ក្រុមអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់បាន ដោយផ្អែកលើលក្ខខណ្ឌទាំងបី គឺ លក្ខខណ្ឌទី១ ៖ ភាគីបានទទួលការអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។

ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ**

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីកម្មករនិយោជិត មកចូលរួមសវនាការអាជ្ញាកណ្តាលត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៦៥៧ កប/អក/វក/លកអ. ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ និងតាមរយៈទូរស័ព្ទនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ដោយបានបញ្ជាក់អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងច្បាស់លាស់ នៃសវនាការអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករនិយោជិតមិនបានមកទទួលលិខិតអញ្ជើញនេះ ពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។ លើសពីនេះ មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើទំនាក់ទំនងតាមរយៈទូរស័ព្ទ និងបានជូនដំណឹងទៅភាគីកម្មករនិយោជិតបន្ថែមទៀតនៅថ្ងៃសវនាការ នាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល។ ហេតុនេះ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតពិតជាបានទទួលការអញ្ជើញ និងជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែង នៃសវនាការអាជ្ញាកណ្តាល ពីសំណាក់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ *"បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល"* នៅក្នុងប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ ខាងលើ មានន័យថា ភាគីត្រូវតែ ១) មានវត្តមាននៅក្នុងសវនាការ និង២) ចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា ៖

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

THE ARBITRATION COUNCIL

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ និង

ឃ-ដំណាក់កាលសវនាការដល់អង្គសេចក្តី

បន្ថែមលើនេះ ប្រការ ១៩ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា ៖ *"ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីភាគីនោះ"* ។

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត មិនបានមានវត្តមាននៅថ្ងៃសវនាការអាជ្ញាកណ្តាលទេ ហើយក៏មិនបានចាត់ឱ្យមានអ្នកតំណាងត្រឹមត្រូវ ដើម្បីតំណាងពួកគាត់នៅក្នុងសវនាការនោះដែរ។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា លក្ខខណ្ឌទី២ ក៏ត្រូវបានបំពេញដែរ ។

**លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន**

ក្នុងករណីនេះ ភាគីកម្មករនិយោជិតមិនបានផ្តល់ហេតុផលណាមួយត្រឹមត្រូវ សម្រាប់ការមិនចូលរួមសវនាការនេះទេ។ ពោលគឺ នៅពេលដែលមន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើទំនាក់ទំនងតាមរយៈទូរស័ព្ទទៅភាគីកម្មករនិយោជិត នៅថ្ងៃសវនាការនាថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៣ វេលាម៉ោង ២ រសៀល ភាគីកម្មករនិយោជិត គ្រាន់តែបានប្រាប់មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលវិញថា មិនអាចចូលរួមសវនាការទេ ដោយមានការរវល់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីកម្មករនិយោជិតមិនបានផ្តល់មូលហេតុត្រឹមត្រូវ សម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

សរុបសេចក្តីមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹង ក្នុងការធ្វើការទាមទារ និងការពារចំពោះការទាមទាររបស់ខ្លួន ប៉ុន្តែ ភាគីកម្មករនិយោជិតបានជ្រើសរើសយកការមិនចូលរួមនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹង របស់ភាគីកម្មករនិយោជិត ដែលជាភាគីដើមបណ្តឹង។

ដូច្នេះ យោងតាមការបកស្រាយមកខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល នៃសំណុំរឿងលេខ ១៣០/១៣-ឃែនធើរេន អឺភែរីល នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ១៣០/១៣-ឃែនធើរេន អឺភែរីល។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ីខ សុទ្ធី**

ហត្ថលេខា ៖ ----------------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖ ----------------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ----------------------------------------

THE ARBITRATION COUNCIL